# របាយការណ៍ពីការផ្លាស់ប្តូរ សំរាប់ CalWORKs និង CALFRESH

| ឈ្មោះសំណុំរឿង : | |
|---|---|
| លេខសំណុំរឿង : | |
| លេខបុគ្គលិក : | |

**ពីព្រោះតែអ្នកទទួល CalWORKs អ្នកត្រូវតែរាយការណ៍ក្នុងពេល 10 ថ្ងៃ នៅពេលប្រាក់ចំណូលរបស់អ្នកសរុបទាំងអស់ គ្រប់កំរិតដែលកំណត់។**
អ្នកត្រូវតែរាយការណ៍ នៅពេលណាមួយដែលប្រាក់ចំណូលប្រចាំខែសរុបទាំងអស់នៃក្រុមគ្រួសាររបស់អ្នក មានច្រើនជាង កំរិតប្រាក់ចំណូលត្រូវរាយការណ៍ (Income Reporting Threshold, IRT) របស់អ្នក នៅពេលបច្ចុប្បន្ន។

| | |
|---|---|
| ទំហំគ្រួសាររបស់អ្នក គឺ | __________ |
| ប្រាក់ចំណូលរបស់អ្នកបច្ចុប្បន្ន គឺ | $__________ |
| **IRT របស់អ្នក គឺ** | $__________ |

## តើរាយការណ៍របៀបណា?

បើប្រាក់ចំណូលរបស់អ្នក សរុបទាំងអស់មានច្រើនជាងចំនួន IRT ដែលចុះរាយនៅខាងលើ អ្នកត្រូវតែរាយការណ៍ទៅខោនធី **ក្នុងពេល 10 ថ្ងៃ។** អ្នកអាចរាយការណ៍ព័ត៌មាននេះទៅខោនធី ដោយទូរស័ព្ទទៅខោនធី ឬសរសេរសំបុត្ររាយការណ៍វា។

ពាក្យ “ប្រាក់ចំណូលប្រចាំខែសរុបទាំងអស់” យើងចង់មានន័យទៅលើ :

- ➪ ប្រាក់អ្វីៗដែលអ្នកទទួល (ទាំងប្រាក់រកបាន **និងមិនរកបាន)**។
- ➪ ចំនួន*មុន* ការកាត់ចេញអ្វីមួយ។ (ឧទាហរណ៍នៃការកាត់ចេញគឺ : ពន្ធ, សូស្យាល់សឹគ្យូរិទី ឬការបរិច្ចាគចូលនិវត្តន៍, បំណុលទាមទារ, ល។)។

## តើមានអ្វីនឹងកើតឡើង?

- ➪ អត្ថប្រយោជន៍របស់អ្នកអាចនឹងបានបន្ថយ ឬបញ្ឈប់ យោងទៅលើប្រាក់ចំណូលមានច្រើនជាង IRT របស់អ្នក។
- ➪ IRT របស់អ្នក អាចនឹងផ្លាស់ប្តូរ នៅពេលប្រាក់ចំណូលរបស់អ្នកផ្លាស់ប្តូរ ឬនៅពេលមានមនុស្សរើចូល ឬចេញពីផ្ទះរបស់អ្នក។
- ➪ ខោនធីនឹងជំរាបអ្នកឲ្យដឹង ជាលាយល័ក្ខណ៍អក្សរ នៅរាល់ពេល IRT របស់អ្នកផ្លាស់ប្តូរ។
- ➪ អ្នកក៏ត្រូវរាយការណ៍ ក្នុងកំឡុងពេល ការអនុម័តជាសាថ្មី/ការបញ្ជាក់ជាសាថ្មី (redetermination/recertification, RD/RC) របស់អ្នកជាប្រចាំឆ្នាំ នូវប្រាក់ចំណូលទាំងអស់ ហើយក្រដាសបំពេញ RD/RC ក៏សួរអំពីការនេះដែរ សូម្បីតែបើអ្នកបានរាយការណ៍ប្រាក់នោះរួចហើយក៏ដោយ។

## ពិន័យសំរាប់ការមិនរាយការណ៍

បើអ្នកមិនរាយការណ៍ នៅពេលប្រាក់ចំណូលរបស់អ្នកមានច្រើនជាងកំរិត IRT សំរាប់ក្រុមគ្រួសាររបស់អ្នក នោះអ្នកអាចនឹងទទួលអត្ថប្រយោជន៍ច្រើនជាងដែលអ្នកគប្បីទទួល។ អ្នក**ត្រូវតែ**សងអត្ថប្រយោជន៍អ្វីមួយដែលលើសវិញ ដែលអ្នកបានទទួលយោងលើប្រាក់ចំណូល ដែលអ្នកមិនបានរាយការណ៍។ បើអ្នកមិនរាយការណ៍ដោយចេតនា ដើម្បីព្យាយាមឲ្យបានអត្ថប្រយោជន៍ច្រើន នេះគឺហៅថាការគៃបន្លំ ហើយអ្នកអាចនឹងបានជាប់ចោទនៃបទឧក្រិដ្ឋ។

**បើអ្នកទទួល CalWORKs អ្នកក៏ត្រូវតែរាយការណ៍ អំពីអ្វីៗនៅខាងក្រោម ក្នុងពេល 10 ថ្ងៃ នៃពេលវាកើតឡើង :**

1. នៅពេលណាមួយ មានមនុស្សរើចូល ឬចេញ ពីក្រុមគ្រួសាររបស់អ្នក។
2. នៅពេលណាមួយ មានមនុស្សនៅជាមួយ ឬនៅក្នុងក្រុមគ្រួសាររបស់អ្នក ដែលមានការជាប់ទោសបទឧក្រិដ្ឋទាក់ទងនឹងគ្រឿងញៀន *ដែលមិនបានរាយការណ៍ពីមុន។*
3. នៅពេលណាមួយ មានមនុស្សនៅជាមួយ ឬនៅក្នុងក្រុមគ្រួសាររបស់អ្នក ដែលមានការបំពានលក្ខខ័ណ្ឌនៃការសាកល្បងខ្លួន ឬលក្ខខ័ណ្ឌនៃការដោះលែង។
4. នៅពេលណាមួយ មានមនុស្សនៅជាមួយ ឬនៅក្នុងក្រុមគ្រួសាររបស់អ្នក ដែលកំពុងតែរត់គេចវេះពីច្បាប់។
5. នៅពេលណាមួយ អ្នកផ្លាស់ប្តូរអាសយដ្ឋាន។

**បើអ្នកទទួល CalFresh អ្នកក៏ត្រូវតែរាយការណ៍ អំពីអ្វីៗនៅខាងក្រោម ក្នុងពេល 10 ថ្ងៃ នៃពេលវាកើតឡើង :**

1. របាយការណ៍ជាចាំបាច់ទាំងអស់ គឺបានតម្រូវសំរាប់ CalWORKs ក្រៅពី IRT (មើលលេខ 1-5 ខាងលើ)។
2. អ្នកបានផ្លាស់ប្តូរនូវប្រភពប្រាក់ចំណូល រួមទាំងចាប់ផ្តើមធ្វើការ, ឈប់ធ្វើការ ឬការដូរការងារ;
3. ការផ្លាស់ប្តូរប្រាក់ចំណូលរកបាន ដោយច្រើនជាង $100។
4. ការផ្លាស់ប្តូរប្រាក់ចំណូលឥតរកបាន ដោយច្រើនជាង $50 (លើកលែងតែសំរាប់ CalWORKs ឬ General Assistance)។
5. ការផ្លាស់ប្តូរថ្លៃជួលផ្ទះ ឬទឹកភ្លើង (ជរាបតែបើអ្នកផ្លាស់លំនៅ)។
6. ការផ្លាស់ប្តូរអ្វីមួយ នូវចំនួននៃប្រាក់ឧបត្ថម្ភកូន តុលាការបានបញ្ជា។
7. បើអ្នកគឺជា មនុស្សពេញវ័យមានរូបកាយអាចធ្វើការបានគ្មានមនុស្សនៅក្នុងបន្ទុក (Able Bodied Adult Without Dependents, ABAWD) អ្នកត្រូវតែរាយការណ៍ នៅពេលណាមួយដែលម៉ោងធ្វើការ ឬ ការហ្វឹកហ្វឺនរបស់អ្នក ធ្លាក់ចុះតិចជាង 20 ម៉ោងក្នុងមួយអាទិត្យ ឬ 80 ម៉ោងក្នុងមួយខែ។

## ការរាយការណ៍ព័ត៌មានដោយស្ម័គ្រចិត្ត

អ្នកក៏អាចរាយការណ៍ដោយស្ម័គ្រចិត្ត អំពីការផ្លាស់ប្តូរ ទៅខោនធីនៅពេលណាក៏បានដែរ។ *ការរាយការណ៍ពីការផ្លាស់ប្តូរខ្លះ អ្នកអាចនឹងទទួលអត្ថប្រយោជន៍ច្រើនទៀត។* ឧទាហរណ៍ :

- ជនណាម្នាក់នៅក្នុងផ្ទះ ក្លាយជាមានផ្ទៃពោះ។
- ជនណាម្នាក់ទទួលជំនួយប្រាក់ មានសេចក្តីត្រូវការពិសេស ដូចជា : ការមានផ្ទៃពោះ, របបអាហារពិសេសបានចេញវេជ្ជបញ្ជាដោយវេជ្ជបណ្ឌិត, ក្រុមគ្រួសារមានអាសន្ន, ល។
- សំរាប់ CalFresh វិញ បើជនណាម្នាក់ដែលពិការ ឬមានអាយុ 60 ឆ្នាំ ឬចាស់ជាង មានការចំណាយពីហោប៉ៅថ្មី ឬច្រើន ទៅលើតម្លៃពេទ្យ។